ថ្ងៃទី1 ខែធ្នូ ឆ្នាំរេយវ៉ា 2 (ឆ្នាំ2020)
ទីភ្នាក់ងារសេវាកម្មអន្តោប្រវេសន៍

ចំពោះអ្នកដែលមិនអាចត្រឡប់ទៅវិញដោយសារការរាតត្បាតនៃជម្ងឺកូវិដ ហើយមានការលំបាកក្នុងការទ្រទ្រង់ជីវភាពរស់នៅៗជប៉ុន ដែលចង់ធ្វើការ (ធ្វើការគិតប្រាក់ម៉ោង)

ក្រោមស្ថានភាពនៃការរាតត្បាតនៃជម្ងឺកូវិដ ចំពោះជនបរទេសដែលមិនអាចត្រឡប់ទៅប្រទេស ឬកន្លែងដែលខ្លួនរស់នៅវិញបាន ហើយជួបការលំបាកក្នុងការទ្រទ្រង់ជីវភាពរស់នៅៗប្រទេសជប៉ុន រដ្ឋាភិបាលជប៉ុនទទួលស្គាល់ឱ្យជននោះធ្វើការបានត្រឹម 28ម៉ោង (ធ្វើការគិតប្រាក់ម៉ោង)។

ជនដែលចង់ធ្វើការ ហើយស្របនឹងល័ក្ខខ័ណ្ឌពីរខាងក្រោមនេះ សូមទៅដាក់ពាក្យសុំការអនុញ្ញាតឱ្យធ្វើសកម្មភាពក្រៅលក្ខណៈសម្បត្តិស្នាក់នៅ តាមមន្ទីរអន្តោប្រវេសន៍តំបន់។

1 ការដាក់ពាក្យសុំអនុញ្ញាតឱ្យធ្វើសកម្មភាពក្រៅលក្ខណៈសម្បត្តិស្នាក់នៅ (ព័ត៌មានលំអិត សូមមើលកន្លែងនេះ។)

2 ល័ក្ខខ័ណ្ឌ

(1) លក្ខណៈសម្បត្តិនៃការស្នាក់នៅបច្ចុប្បន្ន មិនអាចធ្វើការបាន

(2) មានការលំបាកក្នុងការត្រឡប់ទៅប្រទេសខ្លួនវិញ

(3) មានការលំបាកក្នុងការទ្រទ្រង់ជីវភាពរស់នៅរហូតដល់ពេលអាចត្រឡប់ទៅវិញ ដោយសារតែនៅជប៉ុន គ្មានរំពឹងថា នឹងបានជំនួយពីសាច់ញាតិរស់នៅជប៉ុន ឬពីស្ថាប័នដែលខ្លួនចំណុះ ជាដើម

3 ឯកសារដែលត្រូវដាក់

(1) សំណូមពាក្យសុំការអនុញ្ញាតឱ្យធ្វើសកម្មភាពក្រៅលក្ខណៈសម្បត្តិស្នាក់នៅ

(2) អ្វីដែលអាចបញ្ជាក់អំពីមូលហេតុសមស្របស្តីពីភាពលំបាកនៃការត្រឡប់ទៅប្រទេសខ្លួនវិញ (ក្នុងករណីដែលបានដាក់ពាក្យសុំប្តូរលក្ខណៈសម្បត្តិស្នាក់នៅជាអាទិ៍ ពេលថ្មីៗនេះហើយ មិនចាំបាច់ដាក់ទៀតទេ)

(3) លិខិតពន្យល់អំពីមូលហេតុ (សូមមើលទម្រង់ឧទាហរណ៍នៅកន្លែងនេះ។)